**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ២៤១៧ ព.ណ.ភព

ថ្ងៃពុធ ១ រោច ខែ ស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ សីហា ឆ្នាំ ២០២០

# សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ ឧកញ៉ា លោក លោកស្រី ដែលជាម្ចាស់សហគ្រាស ផលិតករ សេវាករ ពាណិជ្ជករ និងសាធារណជនទូទៅឲ្យបានជ្រាបថា៖ ក្រុមប្រឹក្សាជំរុញការនាំចេញកម្រាលព្រំ(CEPC) ដែលបង្កើតឡើងដោយក្រសួងវាយនភណ្ឌនៃរដ្ឋាភិបាលឥណ្ឌា នឹងរៀបចំពិព័រណ៍ពាណិជ្ជកម្មកម្រាលព្រំលើកទី៤០ "The 40th INDIA CARPET EXPO-VIRTUAL EXHIBITION" តាមរយៈវេទិកាអេឡិចត្រូនិកដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី ២១ ដល់ ២៥ ខែសីហា ឆ្នាំ ២០២០ ។

**លក្ខណៈសំខាន់នៃពិព័រណ៍នេះមានដូចជា ៖**

- អ្នកទស្សនាអាចប្រើកម្មវិធីលើទូរស័ព្ទចល័តទាំង IOS និង Android ដើម្បីចូលទស្សនាការដាក់តាំងបង្ហាញផលិតផលតាមរយៈវេទិកាអេឡិចត្រូនិក គ្រប់ទីកន្លែង គ្រប់ពេលវេលា
- ការផ្គូផ្គងពាណិជ្ជករ និងកាលានុវត្តភាពក្នុងការរកដៃគូ
- វីដេអូផ្សព្វផ្សាយផលិតផលសក្តានុពលរបស់ក្រុមហ៊ុនល្បីៗ
- មានកម្មវិធីជជែក និង ជួបតាមប្រព័ន្ធវីដេអូជាមួយតំណាងក្រុមហ៊ុន
- មានបន្ទប់ប្រជុំជាលក្ខណៈឯកជនតាមកាលវិភាគផ្ទាល់ខ្លួនតាមរយៈកម្មវិធីលើទូរស័ព្ទចល័ត
- ផលិតផលដែលបានបង្ហាញមានពិពណ៌នាលក្ខណៈលម្អិតដើម្បីជួយសម្រួលដល់ការរកប្រភព
- សិក្ខាសាលាដែលមានវាគ្មិន និងអ្នកជំនាញ ដើម្បីបង្កើនការយល់ដឹងបន្ថែមក្នុងការសម្រេចចិត្ត
- រក្សាការសម្ងាត់ និងសុវត្ថិភាពចំពោះការជជែកពិភាក្សា និងទិន្នន័យផ្សេងៗ។

ដំណឹងនេះចាត់ទុកដូចជាការអញ្ជើញ ឧកញ៉ា លោក លោកស្រីដែលជាម្ចាស់សហគ្រាស ផលិតករ ពាណិជ្ជករ សេវាករ និងម្ចាស់ក្រុមហ៊ុនវិនិយោគ ដែលកំពុងធ្វើធុរកិច្ចលើវិស័យពាក់ព័ន្ធខាងលើ ហើយមានបំណងចូលរួមផ្សព្វផ្សាយពីផលិតផល ឬ សេវាកម្មរបស់ខ្លួន ឬមានគម្រោងស្វែងរកដៃគូពាណិជ្ជកម្ម ក្នុងព្រឹត្តិការណ៍ពិព័រណ៍នេះ សូមបំពេញបែបបទនិងចុះឈ្មោះចូលរួមតាមអនឡាញតាមរយៈគេហទំព័រ: https://cepc.co.in/events/india-carpet-expo-virtual-edition

សូមអរគុណ។

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងពាណិជ្ជកម្ម

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

KINGDOM OF CAMBODIA

Nation - Religion - King

Ministry of Commerce

N° 2467 MOC...D./EA

Phnom Penh, 5 August 2020

## ANNOUNCEMENT

The Ministry of Commerce of the Kingdom of Cambodia has the honor to inform all producers, traders, service providers and entrepreneurs that the Carpet Export Promotion Council (CEPC), set up by Ministry of Textiles, Government of India is organizing "The 40th INDIA CARPET EXPO-VIRTUAL EXHIBITION" from 21st -25th August, 2020.

**Main Features of above Virtual Exhibition:**

- Anywhere any time the show will run on the website and will be accessed at web browser and mobile application including IOS and android using innovative interactive technology creating user friendly 3D immersive virtual experience/environment.
- Seamless match- making opportunity (pre-scheduled/approved meetings).
- Availability of Company and product videos to enhance the experience of the buying/sourcing.
- Chat and video conferencing facility to help easy interactions.
- Artificial Intelligence Driven Matchmaking for Exhibitors as per their requirement.
- Private Meeting rooms, personalized schedule & Mobile App support.
- Products displayed with detailed specifications to facilitate sourcing.
- Webinars bringing speakers/experts to enhance knowledge and decision making.
- The online platform and data related to products as well as online chats & meetings will be totally secured and visible only to the Buyers.

In this regard, the Ministry of Commerce would like to invite all interested entrepreneurs, producers, traders, service providers and investment companies of which their business activities are related to above-mentioned industries, and wish to participate in the event to visit the website: https://cepc.co.in/events/india-carpet-expo-virtual-edition

THANK YOU!